

# ស្ថានភាព
# សេរីភាពមូលដ្ឋាន
# ឆ្នាំ២០២០

# ស្ថានភាព
# សេរីភាពមូលដ្ឋាន
# ឆ្នាំ២០២០

# សេចក្ដីផ្ដើម

របាយការណ៍នេះ ត្រូវបានកត់ត្រា និងប្រមូលចងក្រង នូវទិន្នន័យឡើង ដើម្បីធ្វើការវិភាគ និងពិនិត្យរកមើល ពីផលប៉ះពាល់ដែលបានកើតឡើងពីកំណើន នៃ ការិតត្បិតលើសេរីភាពមូលដ្ឋាន។ ព័ត៌មាននៅក្នុងរបាយការណ៍នេះ ត្រូវបានចងក្រងឡើងពីស្ថានភាពជាក់ស្ដែង ដែលបានជួបប្រទះផ្ទាល់ និងទទួលបានពីក្រុមគោលដៅ និងភាគីពាក់ព័ន្ធទាក់ទងពី ស្ថានភាពសិទ្ធិមនុស្ស និងប្រជាធិបតេយ្យ នៅទូទាំងប្រទេសកម្ពុជា តាមរយៈការិយាល័យសមាគមអាដហុក តាមខេត្តចំនួន១៧ និងរាជធានីភ្នំពេញ ចាប់ពីខែមករាដល់ខែធ្នូ ឆ្នាំ២០២០ ។

សមាគមការពារសិទ្ធិមនុស្សអាដហុក គឺជាអង្គការសង្គមស៊ីវិលដែលធ្វើសកម្មភាពផ្ដោតលើវិស័យលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា។ បេសកកម្មរបស់អាដហុក គឺលើកស្ទួយឲ្យមានការគោរពសិទ្ធិមនុស្សតាមរយៈការអប់រំផ្ដល់ចំណេះដឹង ដល់ប្រជាពលរដ្ឋអំពី សិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការបង្ការកុំឲ្យមានការរំលោភសិទ្ធិមនុស្ស តាមរយៈសកម្មភាពឃ្លាំមើល និងការតស៊ូមតិ ។ របាយការណ៍នេះគឺជា ផ្នែកមួយនៃសកម្មភាពឃ្លាំមើល និងការកត់ត្រាពី ស្ថានភាពរំលោភសិទ្ធិមនុស្សដទៃៗទៀតដែលបានរកឃើញ ដោយយើងផ្ដោតជាសំខាន់ទៅលើការអនុវត្តន៍សិទ្ធិជាមូលដ្ឋានទាំងបីដូចជា សិទ្ធិខាងការបញ្ចេញមតិ សិទ្ធិខាងការជួបប្រជុំ និងសិទ្ធិខាងសមាគម ពីព្រោះសិទ្ធិទាំងបីនេះ គឺជាឧបករណ៍ខ្នាតវង្វាស់ដ៏សំខាន់មួយ សម្រាប់វាស់ការអនុវត្តសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានថា តើប្រទេសមួយមានការអនុវត្តន៍គោលការណ៍ប្រជាធិបតេយ្យ និងសិទ្ធិមនុស្សបានល្អប្រសើរ ឬយ៉ាងណានោះ ។

ក្រៅពីដំណើរការបោះឆ្នោតដោយសេរី ត្រឹមត្រូវយុត្តិធម៌ និងនីតិរដ្ឋ ក ត្តាអនុវត្តសិទ្ធិជាមូលដ្ឋានទាំងបីខាងលើនេះ គឺជាលក្ខណៈវិនិច្ឆ័យដ៏សំខាន់មួយទៀតដែលបានបង្ហាញអំពីភាពខុសគ្នា រវាងសង្គមប្រជាធិបតេយ្យ និងសង្គមផ្ដាច់ការ ។ ក្នុងសង្គមប្រជាធិបតេយ្យប្រជាពលរដ្ឋ គឺជាម្ចាស់អំណាច រីឯមន្ត្រីរាជការ គឺជាអ្នកបំរើរាស្ត្រ ។ ដូច្នេះ ពេលមន្ត្រីបំរើរាស្ត្រមិនបានល្អរាស្ត្រមានសិទ្ធិបញ្ចេញមតិទិតៀនរិះគន់ដល់ការដឹកនាំមិនល្អនោះ ហើយបើមន្ត្រីមិនស្ដាប់ការទិតៀនរបស់រាស្ត្រនោះទេ រាស្ត្រមានសិទ្ធិធ្វើកូដកម្ម ឬបាតុកម្មអហិង្សា ដើម្បីដាក់សំពាធអោយមន្ត្រីនោះស្ដាប់ ឬយកទុក្ខកង្វល់ និងសំណើទាំងឡាយរបស់រាស្ត្រទៅពិចារណា និងខិតខំរកដំណោះស្រាយជូនរាស្ត្រវិញ។ ដូច្នេះ ដើម្បីអាចបញ្ចេញមតិ និងធ្វើសកម្មភាពជួបជុំគ្នាតវ៉ាដោយអហិង្សាបាន គឺប្រជាពលរដ្ឋមានសិទ្ធិចងក្រងគ្នាបង្កើតជា សហគមន៍ សមាគម ឬចូលរួមជាមួយអង្គការមហាជន ដើម្បីជួយគ្នាទៅវិញទៅមក ហើយសិទ្ធិនេះត្រូវបានធានាយ៉ាងជាក់ច្បាស់ នៅក្នុងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ជាតិថែមទៀតផង ។ កត្តានេះហើយ ដែលបង្ហាញឲ្យឃើញកាន់តែច្បាស់ថែមទៀតនូវភាពខុសគ្នារវាងសង្គមប្រជាធិបតេយ្យ និងសង្គមផ្ដាច់ការនោះ ។

យោងតាមមាត្រា៥១ នៃរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ប្រកាន់យករបបប្រជាធិបតេយ្យ សេរី ពហុបក្ស និងគោរពសិទ្ធិមនុស្ស។ ជាមួយគ្នានេះដែរ កម្ពុជាក៏ជារដ្ឋហត្ថលេខីលើលិខិតតុបករណ៍ ច្បាប់សិទ្ធិមនុស្សអន្តរជាតិជាច្រើនរួមមាន កតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ព្រមទាំងអនុសញ្ញាជាច្រើនទៀត ដែលទាក់ទងនឹង

សិទ្ធិមនុស្ស ហើយដែលខ្លឹមសារនៃ កតិកាសញ្ញា និង អនុសញ្ញាទាំងអស់នោះ ត្រូវបានដាក់បញ្ចូលទៅក្នុង រដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ជាតិថែមទៀត ផង។ ជាងនេះទៅទៀត ដើម្បីបញ្ជាក់ឲ្យកាន់តែច្បាស់ ពីភាពគតិយុត្តនៃ ឋានៈរបស់ច្បាប់សិទ្ធិមនុស្សអន្តរ-ជាតិទាំងនោះ នៅក្នុងប្រព័ន្ធច្បាប់ជាតិ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញបានចេញ សេចក្តីសម្រេច ដែលបានធ្វើការបកស្រាយយ៉ាង ច្បាស់លាស់នូវមាត្រា៣១ នៃរដ្ឋធម្មនុញ្ញ ដែលមាន ន័យថា សិទ្ធិសញ្ញាអន្តរជាតិទាំងឡាយណា ដែល កម្ពុជាបានផ្តល់សច្ចាប័ន អាចអនុវត្តដោយផ្ទាល់នៅ ក្នុងច្បាប់ជាតិ ។ ទាំងនេះហើយ ដែលសរបញ្ជាក់ថា រដ្ឋាភិបាលកម្ពុជាត្រូវជាប់កាតព្វកិច្ច គោរព ការពារ និងបំពេញឲ្យខានតែបាន ចំពោះសិទ្ធិមនុស្សទាំងអស់ រួមទាំងសិទ្ធិមញ្ចេញមតិ សិទ្ធិជួបប្រជុំ និងសិទ្ធិចូលរួម សកម្មភាពខាងនយោបាយរបស់ពលរដ្ឋខ្លួន ដូចដែល ខ្លួនបានសន្យាជាឱឡារិក នៅក្នុងកតិកាសញ្ញាស្តីពី សិទ្ធិពលរដ្ឋ និងនយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ។

ជាក់ស្តែងការអនុវត្តន៍បច្ចុប្បន្ន ទាំងមតិជាតិ និងអន្តរជាតិមើលឃើញថា រដ្ឋាភិបាលមិនត្រឹមតែមិន បានយកចិត្តទុកដាក់ក្នុងការធ្វើឲ្យប្រសើរឡើងនូវ សិទ្ធិ ទាំងនោះទេ បែរជាប្រើប្រាស់ និងយកយន្តការ របស់រដ្ឋរួមមាន តុលាការ កំលាំងប្រដាប់អាវុធ និង អាជ្ញាធរសាធារណៈធ្វើការគំរាមកំហែង តាមសង្កត់ រឹតត្បិត និងធ្វើទុក្ខបុកម្នេញទៅលើប្រជាពលរដ្ឋរបស់ ខ្លួន ជាពិសេសទៅលើក្រុមដែលរដ្ឋាភិបាលយល់ថា ពួកគេមានទស្សនៈមិនស្របនឹងខ្លួន ។

តាមរយៈការសង្កេតឃ្លាំមើល ដោយយកចិត្ត ទុកដាក់របស់សមាគមអាដហុកឃើញថា ការរឹតត្បិត តាមសង្កត់ បំភិតបំភ័យ គំរាមកំហែង និងការធ្វើទុក្ខ បុកម្នេញ ដោយរំលោភបំពានទៅលើអ្នក/ក្រុមដែល បានប្រើប្រាស់សេរីភាពបញ្ចេញមតិ ជួបជុំ/ប្រមូលផ្តុំ ធ្វើបាតុកម្មដោយសន្តិវិធី និងការចូលរួមយ៉ាងសកម្ម ខាងសមាគម សហគមន៍ និងនយោបាយ នៅតែបន្ត កើតមានជាបន្តបន្ទាប់នៅឡើយ រួមមានដូចជាៈ

១-ការរំខានពីកងកម្លាំងប្រដាប់អាវុធ ឬអាជ្ញាធរ ករណីពលរដ្ឋ ចូលរួមក្នុងសកម្មភាពរបស់អង្គការ សមាគម សហជីព ដើម្បីធ្វើការចងក្រងសហគមន៍ ការពារផលប្រយោជន៍រួម សហគមន៍ ការទប់ស្កាត់ បទល្មើសនៅពេលកើតមានឡើង ការចែករំលែក ព័ត៌មានករណីវិវាទដីធ្លីជាមួយក្រុមហ៊ុន ឬបុគ្គលមាន អំណាចដែលរំលោភបំពាន ។

២-ការជួបប្រជុំរបស់សហគមន៍ និងអង្គការសង្គម-ស៊ីវិល ដើម្បីពិភាក្សា និងរៀនសូត្រផ្សេងៗ ត្រូវរង ការរិតត្បឹត និងរារាំងពីសំណាក់រដ្ឋអំណាចមូលដ្ឋានខ្លះ ដោយហេតុផលគ្មានច្បាប់អនុញ្ញាត ឬមិនបានជូន ដំណឹងឲ្យអាជ្ញាធរដឹងជាមុន បើទោះសេរីភាពនេះ ត្រូវ បានធានាដោយរដ្ឋធម្មនុញ្ញជាច្បាប់កំពូល ច្បាប់ អង្គការសមាគម និងសេចក្តីណែនាំរបស់ក្រសួង មហាផ្ទៃក៏ដោយ ។



៣-ការរារាំង និងមិនអនុញ្ញាតឲ្យធ្វើបាតុកម្មដោយ សន្តិវិធីតាមផ្លូវច្បាប់ ឲ្យមានការដោះលែងសកម្មជន អ្នកការពារសិទ្ធិមនុស្ស អតីតអ្នកគាំទ្រ និងសកម្មជន នយោបាយ ដែលសិទ្ធិ និងសេរីភាពទាំងនេះ ត្រូវបាន អនុញ្ញាតដោយច្បាប់ដូចមានចែងថា " សិទ្ធិធ្វើបាតុកម្ម ឬដង្ហែដោយសន្តិវិធី ត្រូវយកមកអនុវត្តក្នុងក្របខ័ណ្ឌ

នៃច្បាប់ " មាត្រា៣៧ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៨ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី ដែលអនុញ្ញាតឲ្យប្រជាពលរដ្ឋទាំងឡាយមាន សិទ្ធិក្នុងការធ្វើបាតុកម្មដោយសន្តិវិធី ការសម្តែងមតិដោយសេរីស្របតាមច្បាប់ និងបង្ហាញទុក្ខកង្វល់របស់ខ្លួនដែលត្រូវបានរំលោភបំពាន ដើម្បីឲ្យអង្គការរដ្ឋ ដែលមានតួនាទីទទួលខុសត្រូវក្នុងការដោះស្រាយជូនពួកគាត់។

៤-ការតាមដាន ការឃ្លាំមើលពីសំណាក់អាជ្ញាធរ ការគម្រាមកំហែងពីមន្ត្រីកងកម្លាំងប្រដាប់អាវុធ នៅពេលពលរដ្ឋសហគមន៍បានចូលរួមក្នុងកិច្ច-ការងារសង្គមដូចជា ការជួបជុំសម្តែងមតិ ទាមទារតវ៉ាលើដំណោះស្រាយដីធ្លី ព្រៃឈើ ឬធនធានធម្មជាតិ

ការបង្កើតសហគមន៍ ការចូលរួមក្នុងសកម្មភាពអង្គការ សមាគម សហជីព និងការចងក្រងបណ្តាញចែករំលែកបទពិសោធន៍ ក៏ដូចជា ព័ត៌-មានពីសហគមន៍មួយទៅសហគមន៍មួយ ដែលសកម្ម-ភាពទាំងនេះត្រូវបានផ្តល់ និងគាំពាតាមរយៈសេចក្តីប្រកាសជាសកលស្តីពី សិទ្ធិមនុស្ស " មាត្រា២០ បានចែងថា មនុស្សគ្រប់រូបមានសេរីភាពក្នុងការជួបប្រជុំ ឬការរួមគ្នាជា សមាគមដោយសន្តិវិធី...។" និងមាត្រា៤២ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែទោះបីមានច្បាប់ចែង យ៉ាងណាក៏ដោយ នូវមានកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរមួយចំនួននៅតែបន្តធ្វើការរំលោភបំពានមកលើ សិទ្ធិសេរីភាពទាំងនេះ ដោយសំអាងថា ទទួលបទបញ្ជា ពីថ្នាក់លើ ដើម្បីរួចផុតពីការស្តីបន្ទោស។

៥-ការរារាំង និងប្រព្រឹត្តអំពើហិង្សាពីសំណាក់អាជ្ញាធរ កងកម្លាំងប្រដាប់អាវុធ ក្នុងការបង្ក្រាបមកលើក្រុមប្រជាពលរដ្ឋជួបជុំគ្នា សម្តែងមតិតាមទីសាធារណៈការទាមទារឲ្យមាន ការដោះលែងសកម្មជនគណបក្សនយោបាយ តែងតែទទួលរងនូវការបង្ក្រាបជាញឹកញាប់ រហូតមានប្រើហិង្សា ចាប់ខ្លួន ឃាត់ខ្លួនបណ្តោះអាសន្ន ឃុំខ្លួនបណ្តោះអាសន្ន និងចោទប្រកាន់តាមផ្លូវតុលាការ។

៦-ការសម្តែងមតិតាមបណ្តាញសង្គម ក្រោយគណបក្សសង្គ្រោះជាតិ ត្រូវបានរំលាយតាមអំណាចសាលដីការបស់តុលាការកំពូល សេរីភាពក្នុងការសម្តែងមតិ ការចែករំលែកព័ត៌មាន ត្រូវបានរឹតត្បិតយ៉ាងខ្លាំង ពិសេសក្នុងកំឡុងឆ្នាំ២០២០នេះ ដោយអតីតអ្នកគាំទ្រក៏ដូចជា សកម្មជនមួយចំនួននៃអតីតគណបក្សសង្គ្រោះជាតិ ដោយពួកគេទាំងនោះ ត្រូវបានសមត្ថកិច្ចបង្ខំឲ្យធ្វើកិច្ចសន្យា ឈប់ចែករំលែកព័ត៌មានតាមប្រព័ន្ធបណ្តាញសង្គម ទទួលរងនូវការប្រើអំពើហិង្សាពីសំណាក់ជនមិនស្គាល់មុខ និងទទួលរងការឃាត់ខ្លួន បញ្ជូនខ្លួនមកតុលាការ ដើម្បីធ្វើការចោទប្រកាន់ និងរត់គេចខ្លួនពីការតាមចាប់ខ្លួន ពីការធ្វើទុក្ខបុកម្នេញ ។ ខ្លះទៀតកំពុងតែឃុំខ្លួនបណ្តោះអាសន្នក្នុងពន្ធនាគារ និងកំពុងជាប់ពន្ធនាគារ តាមអំណាចសាលក្រម និងត្រូវបានចោទប្រកាន់ជាច្រើនបទល្មើស និងច្រើនសំណុំរឿងផ្សេងៗគ្នា ដូចជាបទល្មើស " ញុះ-ញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ( មាត្រា៤៩៤ និងមាត្រា ៤៩៥ )" បទ "ញុះញង់ឲ្យមានការរើសអើង (មាត្រា៤៩៦)" បទ "ឧបឃាត (មាត្រា ៤៥១ )" និងបទ " ល្មើសរួមគំនិតក្បត់ ( មាត្រា ៤៥៣ )" នៃក្រមព្រហ្មទណ្ឌ ។ល។

ជាក់ស្តែង ក្នុងរយៈពេលដប់ពីរខែ ( មករា ដល់ធ្នូ ឆ្នាំ២០២០ ) សមាគមអាដហុក បានរកឃើញសកម្មភាពនៃការធ្វើទុក្ខបុកម្នេញ និងការរំលោភបំពានទៅលើសេរីភាពទាំងអស់ខាងលើសរុបចំនួន ១៧៨ករណី តាមរយៈសកម្មភាពឃ្លាំមើលរបស់បុគ្គលិកខ្លួននៅតាមបណ្តាខេត្ត/ក្រុងទាំង១៨។

ចំនួនអាចនឹងមានច្រើនជាងនេះ ដោយករណីខ្លះយើងអាចនឹងមិនទទួលបានព័ត៌មាន ព្រោះតែបុគ្គលិកយើងមានចំនួនតិច និងមិននៅគ្រប់ខេត្ត/ក្រុង តែទោះយ៉ាងណាក៏ចំនួនដែលយើងបានរកឃើញនេះ អាចជាមូលដ្ឋានដ៏សំខាន់មួយ សំរាប់ជាការឆ្លុះបញ្ចាំងពីស្ថានភាព នៃការធ្លាក់ចុះ ចំពោះការអនុវត្តន៍សិទ្ធិសេរីភាពមូលដ្ឋានខាងលើបានផងដែរ ។

## សេរីភាពជួបប្រជុំ/ប្រមូលផ្តុំ

ក. ការជួបប្រជុំ

យ៉ាងហោចមាន ១០៥ករណី នៃសកម្មភាពជួបប្រជុំផ្សព្វផ្សាយ បើកវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាផ្សេងៗ របស់ប្រជាពលរដ្ឋសហគមន៍ និងអង្គការសង្គមស៊ីវិល ត្រូវទទួលរងនូវការរឹតត្បិត និងរារាំង ពីសំណាក់អាជ្ញាធរមូលដ្ឋាន ប៉ូលីស និងកងរាជអាវុធហត្ថ ដែលសកម្មភាពទាំងនោះរួមមានដូចជា ៖

- ការរារាំង និងនិយាយគំរាមមិនឲ្យធ្វើសកម្មភាពជួបជុំ
- ការទាមទាររកលិខិតអនុញ្ញាតិច្បាប់
- ការតម្រូវឲ្យដាក់ឯកសារ កម្មវិធី មេរៀន...
- ការចូលមកថតរូប/ថតសំឡេង/បញ្ជីវត្តមាន
- ការជិះម៉ូតូឆ្វេលចុះឡើងៗ ពេលកំពុងជួបប្រជុំ
- ការហៅទៅសាកសួរ ឬជជីកសួរតាមទូរស័ព្ទនៅមុនពេលសហគមន៍ចេញដំណើរ ឬ ត្រឡប់ពីការចូលរួមសកម្មភាពផ្សេងៗវិញ
- ការដាក់កម្លាំងតាមឃ្លាំមើលជាប្រចាំ
- ការហៅឲ្យធ្វើកិច្ចសន្យាឈប់ជួបជុំ
- ការឃាត់ខ្លួនមួយរយះ

ពិតណាស់ថា សេរីភាពនេះ ត្រូវបានធានាដោយច្បាប់ទាំងច្បាប់ជាតិ និងអន្តរជាតិ ពិសេសរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល ប៉ុន្តែជារឿយៗសកម្មភាពរឹតត្បិតទាំងនោះ អាជ្ញាធរ តែងតែយកលេសថា ធ្វើតាមបញ្ជាមេ (ថ្នាក់លើ) ដើម្បីការពារសុត្ថិភាពប្រជាពលរដ្ឋ ដើម្បីធ្វើរបាយការណ៍ឲ្យថ្នាក់លើ និងដើម្បីថែរក្សា សណ្តាប់ធ្នាប់សាធារណៈជាដើម ។ល។ ហើយដែលទង្វើបែបនេះ គឺផ្ទុយទាំងស្រុងទៅនឹងខ្លឹមសារនៃ ស.ជ.ណ លេខ២០០៦ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ ដែលបានបញ្ជាក់ថា “ សមាគម អង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជីត្រឹមត្រូវស្របតាមច្បាប់ ព្រមទាំងសហគមន៍នានា នៅមូលដ្ឋាន មានសិទ្ធិសេរីភាពពេញលេញ ក្នុងការធ្វើសកម្មភាពក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ជាធរមាន ព្រមទាំងលក្ខន្តិកៈរបស់ខ្លួន ដែលបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ដោយពុំចាំបាច់ជូនដំណឹងដល់អាជ្ញាធរមូលដ្ឋានក្នុងរយៈពេល ០៣ថ្ងៃ មុនពេលចាប់ផ្តើម ធ្វើសកម្មភាពដូចមុននោះឡើយ ” ។

ករណីសិក្សា

ថ្ងៃទី ០៦ តុលា ២០២០ សហគមន៍ដីធ្លីឃុំជីខលើ ស្រុកស្រែអំបិល ខេត្តកោះកុង ប្រមាណ ៥០នាក់ បានជួបជុំគ្នា ដើម្បីប្រារព្ធ និងផ្សព្វផ្សាយទិវាសិទ្ធិលំនៅដ្ឋានពិភពលោកលើកទី៣៥ ឲ្យប្រជាពលរដ្ឋបានដឹង និងជ្រួតជ្រាបពីសារៈសំខាន់នៃសិទ្ធិមានលំនៅឋាន។ នៅវេលាម៉ោង៩ និង៣០នាទីព្រឹក ខណៈពេលដែលតំណាងសហគមន៍ កំពុងថ្លែងអំពាវនាវឲ្យអាជ្ញាធរមានដំណោះស្រាយពីបញ្ហាដីធ្លីរបស់ពួកគេ ស្រាប់តែមាន

កងកម្លាំងសមត្ថកិច្ចនគរបាលប៉ុស្តិ៍ឃុំជីខលើ នគរបាល និងអាវុធហត្ថស្រុកស្រែអំបិល ៦នាក់ បានមករារាំងដំណើរការកម្មវិធីដោយមកសួរនាំអំពីកម្មវិធី គោលបំណង និងសួររកអង្គការដែលជួយឧបត្ថម្ភ ។ មិនតែប៉ុណ្ណោះ សមត្ថកិច្ចបានឆែកសួររកកាត និងថតរូបបុគ្គលិកសមាគមអាដហុក និងបុគ្គលិកអង្គការលីកាដូ ដែលបានទៅចូលរួមឃ្លាំមើលកម្មវិធីនោះទៀតផង ។ បើទោះបីមានការឆ្លើយបំភ្លឺពីតំណាងសហគមន៍រួចក៏ដោយ ក៏សមត្ថកិច្ចនៅតែប្រមូលយកបដាដាក់លើរថយន្ត និងហាមឲ្យប្រជាពលរដ្ឋបញ្ឈប់ធ្វើសកម្មភាព ។ ការប្រកែកតវ៉ាគ្នាអស់រយៈពេលប្រហែល ៣០នាទី ខាងសមត្ថកិច្ចនៅបន្តតែបង្ខំឲ្យប្រជាពលរដ្ឋផ្អាកសកម្មភាព បើពុំនោះពួកគេនឹងប្រើវិធានការដើម្បីបញ្ឈប់ ។ ដោយសារតែមានការរំខាន រារាំង និងគំរាមពីសមត្ថកិច្ចបែបនេះ ទើបប្រជាពលរដ្ឋនាំគ្នាផ្អាកសកម្មភាព ហើយនាំគ្នាទទួលទានអាហារនំបញ្ចុក រួចក៏បែកគ្នាទៅលំនៅឋានរៀងៗខ្លួន ។

## ខ. បាតុកម្មអហិង្សា

ជាមួយនឹងការប្រើប្រាស់ សេរីភាពជួបជុំ/ប្រមូលផ្តុំ នេះដែរ ក៏មានសកម្មភាពបាតុកម្មអហិង្សាដោយសន្តិវិធីចំនួន ២៥ករណី ក្នុងចំណោម ៤០ករណី របស់ប្រជាពលរដ្ឋ កសិករ កម្មករ អាជីវករ សហគមន៍ សហជីព សមាគម សកម្មជនសិទ្ធិមនុស្ស សកម្មជនបរិស្ថាន និងសកម្មជននយោបាយ ដើម្បីទាមទាររកដំណោះស្រាយពីបញ្ហារំលោភដីធ្លី ធនធានធម្មជាតិ ក៏ដូចជា ទាមទារឲ្យមានយុត្តិធម៌សង្គម ដូចជា ឲ្យមានការដោះលែងសកម្មជនព្រំដែន លោក រ៉ុង ឈុន សកម្មជនសិទ្ធិមនុស្ស និងសកម្មជននយោបាយផ្សេងៗទៀតជាដើម ត្រូវទទួលរងនូវការរឹតត្បិតគម្រាមកំហែង និងបង្ក្រាបពីសំណាក់សមត្ថកិច្ច ប៉ូលិស ទាហាន អាវុធហត្ថ ប្រជាការពារ និងអាជ្ញាធរស៊ីវិល ដែលសកម្មភាពទាំងនោះធ្វើឡើងក្រោមរូបភាពៈ

- ការដាក់កម្លាំងឃ្លាំមើល ដែលមានចំនួនហួសហេតុ
- ការរារាំង ដោយប្រើពាក្យសំដីគំរាមកំហែង
- ការរារាំងដោយដាក់របាំងបិទផ្លូវ
- ការបង្ក្រាបដោយហិង្សា
- ការចាប់យាត់ខ្លួនឲ្យធ្វើកិច្ចសន្យា និង
- ការចាប់ឃុំខ្លួនដាក់ពន្ធនាគា ដោយចោទប្រកាន់ប្រព្រឹត្តបទល្មើសផ្សេងៗ ។

នៅក្នុង ឆ្នាំ២០២០ នេះ យ៉ាងហោចណាស់មានបាតុករប្រមាណ ៥នាក់ ត្រូវទទួលរងរបួសពីការបង្ក្រាបដោយអំពើហិង្សា ពីសំណាក់កងកម្លាំងសមត្ថកិច្ច និង ៣៥នាក់ ត្រូវបានចាប់ឃុំខ្លួនដាក់ពន្ធនាគារ ដែលជាទូទៅត្រូវបានចោទប្រកាន់ពីបទ "ញុះញង់ឲ្យបង្កភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម" ។

### ករណីសិក្សា

### ករណីទី១៖ ការបង្ក្រាបដោយហិង្សាលើបាតុករ

កាលពីព្រឹកថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២០ ក្រុមគ្រួសារសកម្មជនអតីតបក្សប្រឆាំង ដែលកំពុងជាប់ឃុំនៅពន្ធនាគារប្រមាណជាង ២០នាក់ បានប្រមូលផ្តុំគ្នាតវ៉ានៅសាលាដំបូងរាជធានីភ្នំពេញ។ ខណៈពេលតវ៉ានោះ សន្តិសុខខណ្ឌ៧មករា ធ្វើការរារាំង និងរុញច្រានទៅលើក្រុមអ្នកតវ៉ា រហូតបណ្តាលឲ្យអ្នកស្រី សេង ចាន់ថន អាយុ៤៩ឆ្នាំ ជាប្រពន្ធលោក ស៊ន់ ធន់ អតីតសមាជិកក្រុមប្រឹក្សាខេត្តកំពង់ធំ និងជាសមាជិក សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ ។ លោកស្រីត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ បន្ទាប់ពីកម្លាំង



រូបថតពីបណ្ដាញសង្គម

សន្តិសុខខណ្ឌ ឈ្មោះ ឆោម ពិសិដ្ឋ បានចាប់បោកផ្ទប់ទៅនឹងផ្លូវថ្នល់ បណ្ដាលឲ្យរងរបួសយ៉ាងធ្ងន់រហូតដល់សន្លប់បាត់បង់ស្មារតី ក្នុងខណៈពេល ដែលអ្នក-ស្រី កំពុងតវ៉ាដោយសន្តិវិធី ឲ្យដោះលែងស្វាមីរបស់អ្នកស្រី ដែលកំពុងជាប់ឃុំក្នុងពន្ធនាគារ ។ អ្នកស្រីសេង ចាន់ថន បានដាក់ពាក្យបណ្ដឹងឈ្មោះ ឆោម ពិសិដ្ឋ ជាសន្តិសុខខណ្ឌ និងបក្ខពួកទៅសាលាដំបូងរាជធានីភ្នំពេញ ពីបទ ហិង្សាចេតនាដោយមានស្ថានទម្ងន់ទោស ដូចមានចែងក្នុងមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ កាលពីព្រឹកថ្ងៃសុក្រ ទី២៥ ខែកញ្ញា ឆ្នាំ២០២០ មកទល់ពេលនេះ តុលាការមិនទាន់បានចាត់វិធានការ លើបណ្ដឹងដែលអ្នកស្រីបានដាក់ប្ដឹងឈ្មោះ ឆោម ពិសិដ្ឋ និងបក្ខពួកនៅឡើយទេ ។

## ករណីទី២៖ ការចាប់ឃុំខ្លួនបាតុករ

កាលពីរសៀលថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២០ សមត្ថកិច្ចក្រុងភ្នំពេញប្រមាណជិត ២០នាក់ និងមន្ត្រីសង្ឃ ៦អង្គ បានចូលទៅឃាត់ព្រះកាយព្រះសង្ឃខ្មែរថាវ៉ៈមួយអង្គព្រះនាម កើត សារ៉ាយ និងយុវជន មាន ព្រហ្មមុនី ជាអនុប្រធានសមាគមនិស្សិតបញ្ញវ័ន្តខ្មែរ ខណៈពេលកំពុងស្នាក់នៅជុំគ្នា ក្នុងទីស្នាក់ការរបស់ខ្លួន នៅជាប់ផ្សារខេស៊ី (KC Market) ស្ថិតក្នុងសង្កាត់ពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។ ការចាប់ខ្លួននេះ ដោយសារតែពួកគេគ្រោងដឹកនាំធ្វើបាតុកម្មដោយអហិង្សា និងសន្តិវិធី ដើម្បីទាមទារឲ្យ




រូបថតពីបណ្ដាញសង្គម



រូបថតពីបណ្ដាញសង្គម

មានយុត្តិធម៌សង្គមនៅទីលានប្រជាធិបតេយ្យ បន្ទាប់ពីលិខិតជូនដំណឹងរបស់ពួកគេ ត្រូវបានបដិសេធដោយសាលារាជធានីភ្នំពេញ ។ លោក មាន ព្រហ្មមុនី និងព្រះតេជគុណ កើត សារ៉ាយ ត្រូវបានតុលាការចោទប្រកាន់ពីបទ "ញុះញង់ឱ្យបង្កភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម " តាមបទប្បញ្ញត្តិ មាត្រា៤៩៤ និងមាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងបញ្ជូនទៅឃុំព្រះកាយ និងឃុំខ្លួននៅពន្ធនាគារព្រៃសរ កាលពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២០ រហូតមកទល់បច្ចុប្បន្ន ។

## សេរីភាពបញ្ចេញមតិ

សិទ្ធិក្នុងការជួបជុំសម្តែងមតិ ដើម្បីទាមទារឲ្យមានការទទួលខុសត្រូវពីអង្គការរដ្ឋ ស្របច្បាប់ដោយសន្តិវិធី មិនធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ត្រូវបានទទួលស្គាល់ និងគាំពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងច្បាប់សិទ្ធិមនុស្សអន្តរជាតិនានារួមមាន សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ។ មាត្រា៤១ រដ្ឋធម្មនុញ្ញ “ ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការជួបប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភនាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។ របបសារព័ត៌មានត្រូវរៀបចំឡើងដោយច្បាប់ ។ “ មាត្រា១៩ សេចក្តីប្រកាសសកល “ មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការមានមតិ និងការសម្តែងមតិ ។ សិទ្ធិនេះ រួមបញ្ចូលទាំងសេរីភាព ក្នុងការប្រកាន់មតិដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរកការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានា ដោយគ្មានព្រំដែន ទោះតាមរយៈ មធ្យោបាយសម្តែងមតិណាក៏ដោយ ។ “ មាត្រា១៩ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ “ មនុស្សគ្រប់រូបមានសិទ្ធិសេរីភាព ក្នុងការមានមតិ និងការសម្តែងមតិ សិទ្ធិនេះរាប់បញ្ចូលទាំងសេរីភាព ក្នុងការប្រកាន់មតិ ដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរកការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានា ដោយគ្មានព្រំដែន ទោះបី មធ្យោបាយតាមការសម្តែងមតិណាមួយក៏ដោយ”។

ទោះយ៉ាងណាក៏ដោយ យើងសង្កេតឃើញថា ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ គឺនៅបន្តធ្លាក់ចុះគួរឲ្យព្រួយបារម្ភ បើធៀបនឹងឆ្នាំកន្លងទៅ ។ តាមការរកឃើញរបស់សមាគមអាដហុក នៅក្នុងឆ្នាំ២០២០ នេះ យ៉ាងហោចមានករណីគំរាមកំហែង និងការរិតត្បិតសេរីភាពនៃការបញ្ចេញមតិចំនួន ៤៨ ករណី ទៅលើប្រជាពលរដ្ឋ តំណាងសហគមន៍ អ្នកសារព័ត៌មាន សហជីព សកម្មជនសិទ្ធិមនុស្ស សកម្មជនដីធ្លី សកម្មជនបរិស្ថាន សកម្មជននយោបាយ និងមន្ត្រីរាជការផងដែរ ។ ការរឹតត្បិតទាំងនេះច្រើនប្រព្រឹត្តឡើងដោយ សមត្ថកិច្ចប៉ូលីស អាជ្ញាធរមូលដ្ឋាន និងការប្រើប្រាស់យន្តការតុលាការ ក្រោមរូបភាព ៖

- ការហៅទៅសាកសួរដោយសមត្ថកិច្ច
- ការចោទប្រកាន់ និងដាក់ក្រោមការត្រួតពិនិត្យដោយតុលាការ
- ការចាប់ឃុំខ្លួនបណ្តោះអាសន្ន
- គេចខ្លួនដោយការគម្រាមកំហែង
- ការបញ្ឈប់ពីការងារ
- ការគំរាមតាមរូបភាពផ្សេងៗ ដូចជា ចេញលិខិតព្រមាន ទទួលរងបណ្តឹង ការបង្ខំឲ្យធ្វើកិច្ចសន្យា និងរងការបង្កហិង្សាពីជនមិនស្គាល់មុខជាដើម។

### ករណីសិក្សា

យុវជន គា សុគុណ អាយុ២២ឆ្នាំ ជាអ្នកចម្រៀងសម័យថ្មី(Rappers) ទោះបីគាត់មិនសូវមានភាពល្បីក្នុងផ្នែកសិល្បៈក្តី ក៏គេបានឃើញចម្រៀងរបស់គាត់ នៅតាមបណ្តាញសង្គមYouTube ។ គាត់រស់នៅជាមួយឪពុកជាជាងជួសជុលទូរទស្សន៍ និងម្តាយជាមេផ្ទះ ក្នុងខ្ទមតូចមួយនៅតាមមាត់ប្រឡាយ ស្ថិតក្នុងភូមិត្រពាំងសេះ

សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប។ ក្រោយពេលយុវជនរូបនេះនិពន្ធ និងច្រៀងចម្រៀង Rap រៀបរាប់ពីស្ថានភាពសង្គមជាក់ស្តែង ដែលរូបគាត់បានជួបពីភាពវេទនារបស់ប្រពលរដ្ឋ ត្រូវបានគេរំលោភបំពានសិទ្ធិ ការរំលោភបំពានដីធ្លី និងបណ្តេញចេញដោយបង្ខំ សកម្មភាពបង្ក្រាបដោយហិង្សារបស់អាជ្ញាធរមកលើពលរដ្ឋ ភាពខុសគ្នារវាងអ្នកមាន និងអ្នកក្រ ភាពអយុត្តិធម៌ក្នុងប្រព័ន្ធតុលាការ ការបាត់បង់ទឹកដី ចំណាកស្រុក និងការរំលោភបំពានផ្សេងៗទៀត នៅក្នុងចំណងជើង "សាសន៍កម្សត់ និងទឹកភ្នែករាស្ត្រ" ។ អត្ថបទចម្រៀងនេះហើយ ដែលធ្វើឲ្យរូបគាត់ត្រូវទទួលរងការចាប់ឃុំខ្លួន និងចោទប្រកាន់ដោយសាលាដំបូងខេត្តសៀមរាបពីបទ "ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍" តាមប្បញ្ញត្តិមាត្រា៤៩៤ មាត្រា៤៩៥ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ដោយត្រូវផ្តន្ទាទោស ដាក់ពន្ធនាគាររយៈពេល ១៨(ដប់ប្រាំបី)ខែ ប៉ុន្តែអនុវត្តទោសក្នុងពន្ធនាគា ១២ (ដប់ពីរ)ខែ ទោសដែលនៅសល់ត្រូវព្យួរ។ បច្ចុប្បន្នយុវជនរូបនេះកំពុងតែជាប់ពន្ធនាគាខេត្តសៀមរាបនៅឡើយ។

## ស្ថានភាពសកម្មជននយោបាយ

នៅបន្ទាប់ពីរដ្ឋសភាជាតិ បានធ្វើវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ មាត្រា៦ ចែងអំពីសកម្មភាពដែលត្រូវហាមឃាត់ " ដែលគណបក្សនយោបាយណាមួយអាចត្រូវបានផ្អាក ឬត្រូវរំលាយចោល រួមទាំងការធ្វើវិទ្ធង្សនាប្រឆាំងនឹងរបបប្រជាធិបតេយ្យ សេរី ពហុបក្ស និងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ធ្វើឱ្យប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ និងធ្វើការញុះញង់ដែលនាំឲ្យមានការបែកបាក់ជាតិ " និង មាត្រា ៤៤ថ្មី(ពីរ) បានកំណត់ថា " ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត គណបក្សនយោបាយដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៦ថ្មី(ពីរ) នៃច្បាប់នេះ និងមាត្រា៧ នៃច្បាប់ស្តីពី គណបក្សនយោបាយ តុលាការអាចសម្រេច ផ្អាកសកម្មភាពគណបក្សនយោបាយនោះ មិនលើសពី ៥ឆ្នាំ រំលាយគណបក្សនយោបាយនោះ " ។ រីឯមាត្រា ៤៥ថ្មី(ស្ទួន) បានកំណត់ថា " គណបក្សនយោបាយ ដែលបានសម្រេចផ្អាកសកម្មភាព មិនត្រូវបានអនុញ្ញាតឲ្យចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតឡើយ ។ ត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឈរឈ្មោះបោះឆ្នោត ក្នុងករណីដែលគណបក្សនយោបាយនោះ ត្រូវបានសម្រេចផ្អាកសកម្មភាព ឬត្រូវបានសម្រេចរំលាយស្របតាមច្បាប់នេះ " ។ ចំណែកមាត្រា១៨ ចែងតម្រូវឱ្យថ្នាក់ដឹកនាំគណបក្សនយោបាយ មិនត្រូវជាបុគ្គលដែលជាទណ្ឌិតជាប់ទោសដាក់ពន្ធនាគារពី បទឧក្រិដ្ឋ ឬបទមជ្ឈឹម ដោយគ្មានការព្យួរទោសឡើយក្នុងខណៈដែលតុលាការ រងការរិះគន់ពីសាធារណៈមតិជាតិ និងមតិអន្តរជាតិថា ខ្វះឯករាជ្យភាព ។

វិសោធនកម្មច្បាប់ទាំង ២មាត្រានេះ ត្រូវបានរដ្ឋសភាអនុម័ត នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ ២០១៧ និងត្រូវបានព្រឹទ្ធសភាអនុម័ត នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ។ នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៩ ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញបានសម្រេចថា ច្បាប់នេះស្របតាមរដ្ឋធម្មនុញ្ញ ហើយនៅថ្ងៃទី៨ ខែមីនា ឆ្នាំ២០១៧ ច្បាប់ស្តីពីវិសោធនកម្មនេះ ត្រូវបានចុះហត្ថលេខាប្រកាសឲ្យប្រើដោយប្រធានព្រឹទ្ធសភាលោក សាយ ឈុំ ក្នុងនាមជាប្រមុខរដ្ឋស្តីទី ខណៈដែលព្រះមហាក្សត្រ នរោត្តមសីហមុនី ទ្រង់គង់នៅក្រៅប្រទេស ។ ច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលត្រូវបានអនុម័ត នៅខែមីនា ឆ្នាំ២០១៥ រឹតត្បិតសេរីភាពបញ្ចេញមតិ ជាពិសេសក្នុងអំឡុងពេលនៃការធ្វើយុទ្ធនាការ ។

ដោយសារតែ វិសោធនកម្មច្បាប់ខាងលើនេះហើយ ដែលបណ្ដាលឲ្យអតីតប្រធានគណបក្សសង្គ្រោះជាតិ លោក សម រង្ស៊ី ត្រូវលាចេញពីតំណែង ។ លោក កឹម សុខា ដែលទើបតែបានឡើងជំនួសតំណែងជាប្រធានបក្ស ក៏ត្រូវបានកម្លាំងសមត្ថកិច្ចចូលទៅចាប់ខ្លួនដល់ក្នុងគេហដ្ឋានទាំងយប់ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៧ ហើយបញ្ជូនទៅឃុំខ្លួននៅពន្ធនាគារ "មេត្រពាំងផ្លុង" ក្នុងខេត្តត្បូងឃ្មុំ ដោយចោទប្រកាន់ ពីបទសន្ធិដ្ឋិភាពជាមួយបរទេស តាមមាត្រា៤៤៣ នៃក្រមព្រហ្មទណ្ឌ ។ ជាមួយគ្នានេះដែរ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ តុលាការកំពូល តាមរយៈបណ្ដឹងរបស់ក្រសួងមហាផ្ទៃ បានចេញសាលដីកាប្រកាសសម្រេចរំលាយគណបក្សសង្គ្រោះជាតិដោយចោទ ថាបានបំពានបញ្ញត្តិច្បាប់ស្ដីពី គណបក្សនយោបាយតាមមាត្រា៦ ដែលទើបវិសោធកម្មថ្មីៗ ចែងថា "គណបក្សនយោបាយណាមួយអាចត្រូវបានផ្អាក ឬត្រូវរំលាយចោល រួមទាំងការធ្វើវិទ្ធង្សនាប្រឆាំងនឹងរបបប្រជាធិបតេយ្យ សេរី ពហុបក្ស និងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ធ្វើឲ្យប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ និងធ្វើការញុះញង់ដែលនាំឱ្យមានការបែកបាក់ជាតិ " និងមាត្រា៧ ចែងថា គ្រប់គណបក្សនយោបាយមិនត្រូវស្ថិតនៅក្រោមការបង្គាប់ ឬបញ្ជារបស់គណបក្សនយោបាយបរទេស ឬរដ្ឋាភិបាលបរទេស ។ សាលដីកានេះ បានហាមឃាត់ថ្នាក់ដឹកនាំនៃគណបក្សសង្គ្រោះជាតិចំនួន ១១៨រូប មិនឲ្យធ្វើនយោបាយរយៈពេល ៥ឆ្នាំ ។ បន្ទាប់ពីមានសាលដីកានេះ កៅអីសមាជិករដ្ឋសភា ៥៥រូប និងសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ចំនួន ៥០០៧នាក់ត្រូវបាន គជប យកទៅធ្វើការបែង ចែកទៅឲ្យគណបក្សផ្សេងៗ តាមមាត្រា ១៣៨ ស្ទួន នៃច្បាប់ស្ដីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងតាមមាត្រា២០ថ្មី នៃវិសោធនកម្មច្បាប់ស្ដីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលទើបនឹងបានធ្វើវិសោធនកម្ម ក្នុងឆ្នាំ២០១៧ ។

កត្តានេះហើយដែលធ្វើឲ្យអ្នកគាំទ្រ ជាពិសេសសកម្មជនដែលធ្លាប់តែសកម្ម ហើយនៅបន្តរក្សាជំហរស្មោះស្ម័គ្រជាមួយគណបក្សនេះ ត្រូវទទួលរងនូវការចាប់ខ្លួន ការតាមដាន ការអូសទាញ និងការបំភិតបំភ័យ តាមរូបភាពផ្សេងៗដែលនៅក្នុងឆ្នាំ២០២០នេះ សមាគមអាដហុក បានរកឃើញមានសកម្មជនគណបក្សចំនួន ៥៣នាក់ ទទួលរងការគំរាមកំហែង និងចាប់ឃុំខ្លួន ដោយគ្រាន់តែពួកគេនៅបន្តការជួបជុំ ការទំនាក់ទំនងចែករំលែកព័ត៌មាន ឲ្យគ្នាទៅវិញទៅមក ឬសរសេរសារបង្ហោះតាមបណ្ដាញសង្គមផ្សេងៗ ។ ក្នុងនោះ ១៦នាក់ ត្រូវបានសមត្ថកិច្ចហៅ ទៅសាកសួរឲ្យធ្វើកិច្ចសន្យា និង ១០នាក់ រងការវាយបង្ករបួសស្នាមដោយជនមិនស្គាល់មុខ ដែលជាទូទៅសមត្ថកិច្ចមិនដែលចាប់បានជនដៃដល់ យកមកផ្ដន្ទាទោសឡើយ។ គិតចាប់ពីក្រោយនៃថ្ងៃប្រកាសវិលចូលស្រុករបស់លោក សម រង្ស៊ី នៅឆ្នាំ២០១៩ មានតែមួយករណីគត់ ដែលសមត្ថកិច្ចចាប់ជនសង្ស័យបានក្នុងចំណោមជាង ២០ករណី ដែលសកម្មជននយោបាយត្រូវរងការវាយប្រហារ ។ ជាមួយគ្នានេះដែរក៏មានសកម្មជននយោបាយចំនួន ៣៧នាក់ទៀត ត្រូវបានចាប់ឃុំខ្លួន រួមទាំងលោក សួង សុភ័ណ្ឌ ប្រធានគណបក្សខ្មែរឈ្នះ ដែលភាគច្រើនពួកគេត្រូវបានចោទប្រកាន់ពីបទ " ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ( មាត្រា ៤៩៤ និងមាត្រា ៤៩៥ ) " បទ " ឧបឃាត និងការរួមគំនិតក្បត់ ( មាត្រា ៤៥១ ) " បទ " រួមគំនិតក្បត់ (ម៤៥៣) " នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងមួយចំនួនទៀត បានរត់គេចខ្លួនពីលំនៅដ្ឋាន ដោយសារតែមានការភ័យខ្លាច និងរងដីកាតាមចាប់ខ្លួនពីតុលាការ ។

ពិតណាស់ ស្ថានភាពប្រទេសកម្ពុជានៅ

ក្រោយការបោះឆ្នោតម្តងៗ តែងតែមានជម្លោះខាងនយោបាយកើតឡើង ហើយពេលនោះបញ្ហានៃ ការគោរពសិទ្ធិមនុស្ស ក៏ត្រូវបានធ្លាក់ចុះគួរឲ្យព្រួយបារម្ភណ៍ ។ ប៉ុន្តែបន្ទាប់មកមិនយូរប៉ុន្មាន ជម្លោះទាំងនោះតែងត្រូវបាន ដោះស្រាយសម្របសម្រួលត្រូវគ្នាទៅវិញ ជាក់ស្តែងចាប់ពីក្រោយការបោះឆ្នោតជាតិឆ្នាំ១៩៩៣ ដែលរៀបចំដោយអ៊ុនតាក់ ( អង្គការសហប្រជាជាតិ ) ការធ្លាក់ចុះនៃស្ថានភាពគោរពសិទ្ធិមនុស្សជាពិសេសគឺ ការធ្លាក់ចុះនៃការគោរពនូវសិទ្ធិ សេរីភាពមូលដ្ឋានទាំងបីខាងលើនេះ គឺកើតមានតែក្នុងរយៈពេលនៃ ការបោះឆ្នោតជាតិម្តងៗតែប៉ុណ្ណោះ។ ក្រោយការបោះឆ្នោតរួច ស្ថានភាពនេះ តែងតែមានភាពប្រសើរឡើងវិញខ្លះៗ ជារៀងរាល់លើក ។ ប៉ុន្តែ ចាប់ពីក្រោយការរំលាយគណបក្សសង្គ្រោះជាតិ កាលពីឆ្នាំ២០១៧ រហូតមកទល់នឹងពេលបច្ចុប្បន្ននេះ ស្ថានភាពសិទ្ធិមនុស្សបានធ្លាក់ចុះជាប់ជាប្រចាំ និងពុំទាន់ឃើញមានសញ្ញាណាណាមួយដែលបង្ហាញថា នឹងមានភាពប្រសើរឡើងវិញសោះ ។ ជម្លោះនយោបាយរវាងអតីតគណបក្សសង្គ្រោះជាតិ និងគណបក្សកាន់អំណាច ដែលមានតាំងពីពេលនោះមក គឺជាមូលហេតុចម្បង នៃការធ្លាក់ចុះការគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាននេះ ។ អ្នកនយោបាយ និងសកម្មជន នៃគណបក្សប្រឆាំង គឺជាអ្នកដែលរងគ្រោះធ្ងន់ធ្ងរជាងគេ ក្រៅពីនោះនៅមានសកម្មជនអ្នកការពារសិទ្ធិមនុស្ស អ្នកបញ្ចេញមតិតាម បណ្តាញព័ត៌មានសង្គម អ្នកសារព័ត៌មានមួយចំនួន ជនរងគ្រោះដីធ្លី និងធនធានធម្មជាតិ មានការបង្ក្រាបនៅពេលចេញមុខទាមទារតាំម្តងៗ បុគ្គលិកអង្គការសង្គមស៊ីវិលនានា ក៏ត្រូវបានអាជ្ញាធរបង្កការរំខានតាមរូបភាពផ្សេងៗ ក្នុងការបំពេញការងាររបស់ខ្លួនផងដែរ ។

## អនុសាសន៍

- ធ្វើសម្បទាននយោបាយក្នុងស្មារតីបង្រួបបង្រួមជាតិ ពីគណបក្សកាន់អំណាច ដើម្បីមានដំណោះស្រាយនយោបាយ អោយបានមុនការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ ឆ្នាំ២០២២ នេះ គឺជាកត្តាដ៏សំខាន់ដែលនាំឲ្យមានស្ថានភាពប្រសើរឡើងវិញ នៃការគោរពសិទ្ធិមនុស្ស ។
- ការដោះលែង និងទម្លាក់ចោលការចោទប្រកាន់នានាទាំងអស់ពីតុលាការ ចំពោះអ្នកនយោបាយ សកម្មជននយោបាយ ក៏ដូចជាអ្នកបញ្ចេញមតិខាងកិច្ចការសង្គម បរិស្ថាន និងនយោបាយ ។
- ស្នើធ្វើវិសោធនកម្មលើច្បាប់អង្គការ សមាគម ឲ្យបានទៅដល់រដ្ឋសភា ដើម្បីធ្វើវិសោធនកម្មអោយបាន ដូចសេចក្តីស្នើ នៅក្នុងឆ្នាំ២០២១ នេះ ។
- ធ្វើវិសោធនកម្មអោយបានប្រសើរឡើងវិញនូវច្បាប់ គណបក្សនយោបាយ យ៉ាងហោចណាស់អោយបានប្រហាក់ប្រហែលនឹង មុនឆ្នាំ២០១៧ ។
- ដាក់វិន័យ ឬទណ្ឌកម្ម ឬដាក់ទោសតាមច្បាប់ ចំពោះមន្ត្រីអាជ្ញាធររដ្ឋ ដែលបានរំលោភបំពានលើ សិទ្ធិសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ដែលមិនបានអនុវត្តតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងមហាផ្ទៃ ។
- កែលំអរប្រព័ន្ធយុត្តិធម៌ក្នុងការអនុវត្តច្បាប់ នៅតាមស្ថាប័នតុលាការ ដោយយកមាត្រា៥ ក្រមព្រហ្មទណ្ឌ មកអនុវត្តឲ្យបានម៉ឺងម៉ាត់ ដោយមិនត្រូវបកស្រាយពន្លាត ដើម្បីចោទប្រកាន់លើពលរដ្ឋដែលគ្រាន់តែប្រើសិទ្ធិបញ្ចេញមតិ និងជួបជុំគ្នា ដោយសន្តិវិធីក្នុងការទាមទាឲ្យមានការទទួលខុសត្រូវពីអង្គការរដ្ឋ ( ដូចមានចែងក្នុងមាត្រា៣៩ រដ្ឋធម្មនុញ្ញ ) ទៅតាមមាត្រា ៤៩៤ មាត្រា ៤៩៥ មាត្រា ៤៩៦ នៃក្រមព្រហ្មទណ្ឌ ។

